ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




ក ស វ

# Work Activities

ប្រចាំខែកញ្ញា ឆ្នាំ២០១៧



# មាតិកា

| ល.រ បរិយាយ | លេខទំព័រ |
|---|---|


I- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត(ក្រុម RIA)

១- ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី ថ្លែងក្នុង**សិក្ខាសាលាស្តីពីវឌ្ឍន៍ភាពនៃកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ** ១-៣

២- ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបើកសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមប្រធានបទ “**ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន**” ៤-៦

៣- ឯកឧត្តម **ឱន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទីស្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបិទសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមប្រធានបទ “**ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន**” ៧-៩

II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែសីហា ឆ្នាំ២០១៧ ១០-១៧

III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៧ ១៨-១៩

# I- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (ក្រុម RIA)

## ១- ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុក បេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី ថ្លែងក្នុង សិក្ខាសាលាស្តីពីវឌ្ឍន៍ភាពនៃកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ



កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧ ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត បានរៀបចំសិក្ខាសាលាស្តីពីវឌ្ឍន៍ភាពនៃកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ អនុប្រធាន សមាជិក សមាជិកា ECOSOCC និងថ្នាក់ដឹកនាំមន្ត្រីអគ្គលេខាធិការដ្ឋាននៃ ECOSOCC ព្រមទាំងមន្ត្រីនៃក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត។

ក្នុងឱកាសថ្លែងបើកអង្គសិក្ខាសាលានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសំដែងសេចក្តីគោរព និងអរគុណជាអនេកប្បការចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានយល់ព្រមឲ្យបង្កើតគម្រោងRIA និងកម្មវិធីថ្នាក់ជាតិនេះឡើង នៅក្រោមការគ្រប់គ្រងរបស់

ECOSOCC។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានរំលឹកគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចវិបុលបញ្ញា **សុខ អាន** ដែលមានជំនឿលើ ECOSOCC និងបានណែនាំ ចង្អុលបង្ហាញ និងគាំទ្រយ៉ាងខ្លាំងដល់កម្មវិធីRIA។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានលើកឡើងថា ការងារRIAមិនមែនជាការងារនីត្យានុកូលភាពនោះទេ។ ការអនុវត្តRIA មិនប៉ះពាល់ ឬជាន់សមត្ថកិច្ច និងភារកិច្ចជាមួយគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនោះទេ ព្រោះមួយនិយាយពីទម្រង់នៃការតាក់តែង រីឯមួយទៀតគឺការវិភាគអំពីផលប៉ះពាល់តែប៉ុណ្ណោះ។ ការងារRIA គឺជាការងារវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្តណាដែលមានផលប៉ះពាល់ដល់ធុរកិច្ច បរិស្ថាន និងសង្គម ដើម្បីជៀសវាង ឬកាត់បន្ថយជាអតិបរិមានៃផលប៉ះពាល់អវិជ្ជមាន និងផ្តល់ព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយជូនថ្នាក់ដឹកនាំ ដើម្បីងាយស្រួលក្នុងការសម្រេច។ ការអនុវត្តRIA នឹងផ្តល់ផលចំណេញច្រើន ដែលប្រទេសអភិវឌ្ឍជាសមាជិក OECD ទទួលស្គាល់យ៉ាងទូលំទូលាយអស់រយៈពេលជាច្រើនទសវត្សមកហើយ ដូចជាលិខិតបទដ្ឋានគតិយុត្តមានគុណភាពខ្ពស់ នាំឲ្យអភិបាលកិច្ចល្អ ជំរុញកំណើនសេដ្ឋកិច្ច បង្កើនតម្លាភាព គណនេយ្យភាព និងជំនឿទុកចិត្តពីសាធារណជននិងធុរកិច្ច ជួយកាត់បន្ថយការិយាធិបតេយ្យ ឬវិសាលភាពជាន់គ្នា។ ការអនុវត្តRIA នេះក៏រួមចំណែកដ៏សំខាន់មួយ នៅក្នុងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីសំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឲ្យកាន់តែប្រសើរឡើង ដូចបានបញ្ជាក់ច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការអភិវឌ្ឍន៍ជាតិ។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ិននៃកំណើនសេដ្ឋកិច្ចជាតិ។ ដើម្បីឲ្យសម្រេចបាននូវគោលដៅ



នេះ រាជរដ្ឋាភិបាលបាននឹងកំពុងបន្តអនុវត្ត និងរៀបចំគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រដល់ការអភិវឌ្ឍនៃវិស័យឯកជន។ ម្យ៉ាងទៀត ក្នុងឋានៈជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាន កម្ពុជាត្រូវតែមានសមត្ថភាពប្រកួតប្រជែងខ្ពស់នៅក្នុងទីផ្សារអន្តរជាតិ។ ក្នុងបរិការណ៍នេះ ធុរកិច្ចមិនអាចទទួលយកបន្ទុកចំណាយកាតព្វកិច្ចខ្ពស់បាននោះទេ ពីព្រោះធ្វើឲ្យពួកគេខ្វះផលិតភាព និងមិនមានលទ្ធភាពប្រកួតប្រជែងបាន។ ដូច្នេះ ការអនុវត្តRIA នៅតាមក្រសួង-ស្ថាប័ននឹងជួយដល់វិស័យនេះ តាមរយៈការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់៕



## ២- ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងពិធីបើកសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមប្រធានបទ

## “ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន”




ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) ក្រោមប្រធានបទ **“ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន”**។ មន្ត្រីជំនាញមកពីប្រទេសសមាជិកអាស៊ាន ចំនួន៥ បានចូលរួមក្នុងអង្គសិក្ខាសាលាដែលមាន រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១២-១៣ ខែកញ្ញា ឆ្នាំ២០១៧ នៅសណ្ឋាគារសុខាភ្នំពេញ។

អ្នកជំនាញការងារ RIA ពីប្រទេសសមាជិកអាស៊ាន ចំនួន៥នោះ រួមមាន៖ ឡាវ ហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងវៀតណាម និងជាមួយអ្នកជំនាញការងារ RIA មកពីប្រទេសអូស្ត្រាលី និងអង្គការ សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ ដោយបានពិភាក្សាប្រធានបទ ស្តីពីដំណើរឆ្ពោះទៅការប្រតិបត្តិល្អ ក្នុងនីតិវិធីតាក់តែងបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន។

បន្ទាប់ពីមតិស្វាគមន៍របស់ ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត និងចំណាប់អារម្មណ៍របស់ ឯកឧត្តម Samiuel




T.Tukuafu នាយកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា ឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានមានប្រសាសន៍ថា "នេះគឺជាសិក្ខាសាលាដែលមានឆន្ទៈខ្ពស់បំផុតស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលបានធ្វើឡើងនៅប្រទេសកម្ពុជា ដោយមានវាគ្មិនមកពីប្រទេសសមាជិកអាស៊ាន ចំនួន ៥ប្រទេស"។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ពន្យល់ថា RIA គឺជាការវាយតម្លៃជាប្រព័ន្ធ នៃសំណើលិខិតបទដ្ឋានគតិយុត្ត វាជាឧបករណ៍ ឬជាវិធីសាស្ត្រ ដើម្បីរៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តឲ្យបានល្អ ដែលបង្កើនប្រសិទ្ធិភាពនៃលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយប្រកួតប្រជែង។ វាក៏នឹងបង្កើនតម្លាភាព និងអភិបាលកិច្ចល្អផងដែរ។ នៅកម្ពុជា RIA ពឹងផ្អែកលើការវិភាគ និងការពិគ្រោះយោបល់ដោយផ្អែក លើសុភវិនិច្ឆ័យជាមួយភាគីពាក់ព័ន្ធ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបន្ថែមថា RIA មានប្រព័ន្ធវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តល្អ នឹងជួយដល់ប្រទេសសមាជិកអាស៊ានសម្រេចបាននូវគោលបំណង នៃការប្រតិបត្តិល្អ ក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលបានកំណត់ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន Blueprint និងអាស៊ាន Work Plan ស្តីពីការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្ត។




កម្មវិធី RIA ត្រូវបានឧបត្ថម្ភក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្ដីការគណៈរដ្ឋមន្ត្រី គឺជាទីភ្នាក់ងារប្រតិបត្តិកម្មវិធី RIA ក្រោមការគ្រប់គ្រងរបស់ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ដែលបង្កើតឡើងនៅក្រោមក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីមើលខុសត្រូវកម្មវិធី RIA។ ចាប់តាំងពីចាប់ផ្ដើមនៅកម្ពុជានៅឆ្នាំ២០១១មក វឌ្ឍនភាពជាច្រើនត្រូវបានបង្កើតឡើង ដោយក្រសួងចំនួន១៦ និងស្ថាប័នចំនួន២ កំពុងតែចូលរួមកម្មវិធីនេះ ក្នុងនាមជាទីភ្នាក់ងារអនុវត្ត RIA៕

## ៣- ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទីស្តីទទួលបន្ទុកទីស្តីការការគណៈរដ្ឋមន្ត្រី ក្នុងពិធីបិទសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមប្រធានបទ

## “ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន”




ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប៊ិន ឈិន** រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរសៀលថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧នេះ បានអញ្ជើញចូលរួមបិទ សិក្ខាសាលាស្តីពី RIA ក្រោមប្រធានបទ «ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន» ដែលមានវាគ្មិនអន្តរជាតិ មានបទពិសោធនក្នុងការងារRIA ( ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ) មកពីប្រទេសម៉ាឡេស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី ឡាវ វៀតណាម អូស្ត្រាលី ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការ OECD ចូលរួម។

សិក្ខាសាលាខាងលើនេះ ក៏មានការចូលរួមពីឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត លោកស្រី Jacqueline Lam អ្នកឯកទេសពាណិជ្ជកម្ម ផ្នែកគ្រប់គ្រងសាធារណៈ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម (SEPF) នាយកដ្ឋានអាស៊ីអាគ្នេយ៍ តំណាងធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានរៀបចំធ្វើឡើងរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១២-១៣ ខែកញ្ញា នាសណ្ឋាគារសុខាភ្នំពេញ។

បន្ទាប់ពីឯកឧត្តម **ឃឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី ធ្វើសេចក្តីរាយការណ៍ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប៊ិន ឈិន** បានថ្លែងថា «ខ្ញុំសូមកោតសរសើរដល់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដែលរួមគ្នារៀបចំសិក្ខាសាលានេះ បានអាធឹកអាធ័ម ដំណើរការបានល្អ ដោយមានទាំងវាគ្មិនអន្តរជាតិ មកពីប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ឡាវ ហ្វីលីពីន វៀតណាម អូស្ត្រាលី ធនាគារអភិវឌ្ឍន៍អាស៊ី និងអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OECD) ចូលរួមចែករំលែកបទពិសោធន៍ ក្នុងអនុវត្តការវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្តនៅប្រទេសរៀងៗខ្លួន»។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប៊ិន ឈិន** បានបន្តទៀតថា វេទិការដ៏មានសារសំខាន់នេះ បានធ្វើឲ្យយើងបានយល់កាន់តែយល់ច្បាស់អំពីតម្លៃនិងផលប្រយោជន៍ នៃការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្នុងការរៀបចំតាក់តែច្បាប់ និងលិខិតបទដ្ឋានគតិយុត្តឲ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលឡើង។ ប្រទេសសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ ( OECD ) និងប្រទេសសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ានមួយចំនួន បាននិងកំពុងអនុវត្តការវាយតម្លៃលើ ផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត តែទៅតាមទម្រង់ខុសៗគ្នា។


ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ប៊ិន ឈិន** រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់ថា «យើងក៏ត្រូវចាប់អារម្មណ៍ផងដែរ ចំពោះបទបង្ហាញរបស់ប្រទេសម៉ាឡេស៊ី ឡាវ វៀតណាម។ ពិសោធន៍ពីការអភិវឌ្ឍធនធានមនុស្ស លើកឡើងដោយអ្នកជំនាញពីប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ក៏ត្រូវយកមកពិចារណាផងដែរ សម្រាប់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងកម្មវិធីរបស់យើង។ ពិសោធន៍ពីប្រទេសជឿនលឿនក៏ត្រូវយកមកពិនិត្យ ដើម្បីកែលម្អកម្មវិធីរបស់យើង។ ពិសោធន៍ល្អៗ ពីសិក្ខាសាលានេះនឹងជួយកែលម្អ និងលើកកម្ពស់កម្មវិធី នៃការអនុវត្តការវាយតម្លៃ លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅប្រទេសកម្ពុជា»។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីបានបន្ថែមទៀតថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានយកចិត្តទុកដាក់ខ្លាំងណាស់អំពីប្រសិទ្ធភាព និងប្រសិទ្ធផលនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលជាកត្តាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ និងភាពប្រកួតប្រជែងនៃធុរកិច្ច រួមចំណែកដល់ការលើកស្ទួយជីវភាពរបស់ប្រជាជនឲ្យកាន់តែប្រសើរឡើង និងជួយកាត់បន្ថយភាពក្រីក្រផង៕



រូបភាពក្នុងសិក្ខាសាលាស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
ក្រោមប្រធានបទ
“ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន”



# II- កិច្ចប្រជុំស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែសីហា ឆ្នាំ២០១៧**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គ-លេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហា ឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៤%ធៀបនឹងខែមុន និងកើនឡើង២,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៧,៣% | ប្រេងសាំង: | +៩,៦% |
| ការដឹកជញ្ជូន: | +៤,២% | ប្រេងម៉ាស៊ូត: | +៨,១% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,៥% | ត្រីស្រស់: | +៥% |
| ម្ហូបអាហារ: | +២,៨% | បន្លែ: | +៣,៦% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +១,៣% | សាច់មាន់: | +២,៥% |
| សុខាភិបាល: | +១,៣% | សាច់គោ: | +២,៤% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +១,១% | សាច់ជ្រូក: | +១% |
| ការកំសាន្ត និងវប្បធម៌: | +០,៦% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា P | តុលា P | វិច្ឆិកា P | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,២% | ៣,២% | ២,៥% | ២,៣% | ២,៣% | ២,៦% | ២,៨% | ២,៣% | ២,៣% | | |
| | មុន | ០,៣% | ០,១% | ០,០% | ០,៤% | -០,២% | ០,១% | ០,៣% | ០,៤% | ០,៥% | -០,១% | ០ | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែកញ្ញា តុលា និងវិច្ឆិកា ឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១១.. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

| បម្រែបម្រួលសន្ទស្សន៍ថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុន | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (គ្រាគោល ២០០៦) |
|---|---|
|  |  |





តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | សីហា ២០១៧ | កក្កដា ២០១៧ | សីហា ២០១៦ | *ប្រភេទ* | សីហា ២០១៧ | កក្កដា ២០១៧ | សីហា ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៥០៛/១$ | ៤០៩៨៛/១$ | ៤០៩៦៛/១$ | **បាត/ដុល្លារ** | ៣៣,២១បាត/១$ | ៣៣,៣៤បាត/១$ | ៣៤,៦០បាត/១$ |
| **៛/បាត** | ១២២៛/១បាត | ១២៣៛/១បាត | ១១៨៛/១បាត | **ដុង/ដុល្លារ** | ២២៦៩៨ដុង១$ | ២២៧១១ដុង១$ | ២២២៧០ដុង/១$ |
| **៛/ដុង** | ០,១៧៨៛/១ដុង | ០,១៨០៛/១ដុង | ០,១៨៤៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែសីហា ឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៣៩៩,៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣៤៩,៩លានដុល្លារ (*មធ្យមប្រចាំខែ១០៦% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន១៣៨៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៤៦,៧លានដុល្លារ (*មធ្យមប្រចាំខែ ១០៥% នៃផែនការ*) និងចំណូលមូលធនមានចំនួន១២,៧ ប៊ីលានរៀល (*មធ្យមប្រចាំខែ ២២៤% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង ១៥,៥% និង កើនឡើង២៦,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១១០៩,៩ប៊ីលានរៀល កើនឡើង៥,៨% ធៀបនឹងខែមុន និងកើនឡើង ១៨,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន២៧៧,១ប៊ីលានរៀល កើនឡើង១៨០,៩% ធៀបនឹងខែមុន និងកើនឡើង៥៩,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +៥,៧% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១៦,៨%) | ➢កាស៊ីណូ : +១៦៤% | (+៣៨,៥%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : -៧២,៩% | (-២៦,៩%) |
| ➢ ចំណូលពន្ធដារ: +៨,៦% (អគ្គនាយកដ្ឋានពន្ធដារ) | (+៤០,៣%) | ➢ នេសាទ: +កើនយ៉ាងគំហុក | (+៥០២,៧%) |
| | | ➢សម្បទានរ៉ែ: +២១៩,៩% | (+២៤៧,៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +១០១,១% | (-១៤,៩%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +កើនយ៉ាងគំហុក | (+៦៦,២%) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +២៣,២% | (+២៤,១%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: +៣៨៣៥,៨% | (+៣១៧,៣%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១៣៥៣,៦ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ៣៣៨,៣៩លានដុល្លារ ( *មធ្យមប្រចាំខែ ៨០% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១១៥៥,៨ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៨៦% នៃផែនការ*) និងចំណាយមូលធនមានចំនួន ១៩៧,៨ប៊ីលានរៀល(តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិថយចុះ៦,៦% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤១,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៤៤,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមាន អតិរេកចំនួន ៤៦,១ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ១១,៥លានដុល្លារ (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥-២០១៧

(ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែសីហា ឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុM₂ មានចំនួន ៦៨៣៨៧ប៊ីលានរៀល កើនឡើង២%ធៀបនឹងខែមុន និងកើនឡើង ២០,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង M₂** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃ រូបិយវត្ថុក្រៅធនាគារ៣,៨% ប្រាក់បញ្ញើមានកាល កំណត់និងសន្សំ៥,២% និងប្រាក់បញ្ញើជារូបិយបណ្ណ ១,៧%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែសីហា ឆ្នាំ២០១៧



➢ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៤%នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ M2 ឆ្នាំ២០១៧

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៦,៧% | ១៦,៦% | ១៥,៥% | ១៥,៣% | ១៥,៧% | ១៦,០% | ១៦,៣% | ១៦,៦% | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | ១១,៣% | ១១,៣% | ១១,២% | ១១,១% | ១១,៤% | ១២% | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែសីហា២០១៧: ក្នុងរង្វង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន៨២៣៤លានដុល្លារ កើនឡើង២,៣%ធៀបនឹងខែមុន និងកើនឡើង៣៩,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** : ក្នុងខែនេះមានចំនួន២៥១៧២ប៊ីលានរៀល កើនឡើង ១,១%ធៀបនឹងខែមុន និងកើនឡើង៣៥,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *សីហា ២០១៧* | *កក្កដា ២០១៧* | *សីហា ២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ: ជារៀល | ៦៤០៥៨ | ៦៣៤៨០<br>១០៩៣ | ៥៥៦១៤<br>៧៧៨ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៥២១៤០ | ១១៦៥៧ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៩៩% | ៦,០៥% | ៦,៨០% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៤,៥% | ១៤,៥៣% | ១៧,៣៣% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤២% | ៤,៤៣% | ៤,៥០% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៧៩% | ១១,៧៩% | ១១,៨២% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថាកសិករ | ១៨% | ១៨% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨% | ១៨% | ២៨,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៧,២% | ១៧,៦% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែសីហាឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៧៤,៩ពាន់តោន កើនឡើង១៣%ធៀបនឹងខែមុន ប៉ុន្តែថយចុះ១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢រ៉ែ និងថាមពល:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៧០៦,៨៤GWHមានការកើនឡើង៩,១%ធៀបនឹងខែមុន និងកើនឡើង១៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៤៧៥,៥៧ GWH មានការកើនឡើង១៣៦% ធៀបនឹងខែមុន និងកើនឡើង៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន១៧១,៣២GWHមានការថយចុះ៤៥% ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង ១០៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ឧស្សាហកម្ម:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៦៩៩លានដុល្លារ មានការថយចុះ១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –សីហា ២០១៧ | ចំនួន–កក្កដា ២០១៧ | ចំនួន–សីហា ២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ២៥ | ៩ | ១៣ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦៥៥ | ១៦៣០ | ១៥៤៣ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៩ | ២៤ | ៣១ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១០០ | ២៨ | ៣៩ |

➢សំណង់ (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៦៤៥,៦ពាន់ម$^{២}$ថយចុះ៣១%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១២៧%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង១៧៤,៦លានដុល្លារ ថយចុះ៥២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥៩%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^{២}$ –សីហា២០១៧ | ពាន់ម$^{២}$ –កក្កដា២០១៧ | ពាន់ម$^{២}$ –សីហា២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ៤៣៨ | ៤៣២,៧ | ១៣១,៨ |
| ▪ ឧស្សាហកម្ម | ៣២,៩ | ៣៥៨,៩ | ៤៣,៧ |
| ▪ពាណិជ្ជកម្ម | ១០៥,៧ | ៧៧,១ | ១៥,៣ |
| ▪ ទេសចរណ៍ | ៦៣,៦ | ៥៥,៤ | ៩០,៦ |
| ▪ផ្សេងៗ | ០,២ | ១,៨ | ៣ |
| អនុញ្ញាតសរុប | ៦៤៥,៦ | ៩២៩ | ២៨៤,៦ |

✓ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះ គឺលំនៅដ្ឋាន៦៧,៨៣% និងពាណិជ្ជកម្ម១៦,៣៧%នៃផ្ទៃក្រឡាសរុប។

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–សីហា ២០១៧ | នាក់–កក្កដា ២០១៧ | នាក់–សីហា ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិង ការងារ) | ១៦១៩ | ១២៩៦ | ១៥៧៣ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១៣៦១៦ | ១៣៦១៦ | ១២៦៥៣ |
| អ្នកទទួលបានការងារក្នុងប្រទេស | ១០១១៦ | ៨៩៨០ | ១១៧២១ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៣៥០០ | ៤៦៣៦ | ៩៣២ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | សីហា២០១៧ | កក្កដា២០១៧ | សីហា២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៦៤ | ២៩៣៣ | ៣០,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០ | ២០៦ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៦៤ (១០) | ២០៩ (៧) | ២៥,៤ (០,៦) |
| វិស័យទេសចរណ៍ | ០ | ២៥១៩ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ០ | ៥,១ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៧ | ២៨ | ៩ |
| បង្កើតការងារ (ពាន់នាក់) | ១៣ | ៣៥ | ៥,៨ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន ៨៣៣,៥ពាន់តោន កើនឡើង១៤%ធៀបនឹងខែមុន និង កើនឡើង២៨%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ:

តារាង៤.៥.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:-១៥% | (-២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:+២៣៦% | (+១៨%) |
| ▪ កំពង់ផែកំពង់សោម:+៣០% | (+៥៣%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +២៧% | (+១៣%) |

### ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៨,៩ | +១៤% | +២៤% |
| ក្នុងនោះទទួល | ២,៧ | +២% | +១១% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១០២,៧ | +៦% | +៤% |
| ក្នុងនោះទទួល | ៥៦,១ | +៣% | +១៩% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៤៥៩,៩ | +៣% | -១៧% |
| ក្នុងនោះហៅចូល | ៧២៩,៧ | +៥% | -២០% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១១៧៧៩ | +៣% | +១៨% |
| ក្នុងនោះហៅចូល | ១១៧១៣,៨ | +៣% | +១៨% |

### ➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៥,៨ | ៥% | ៨% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៥០,៧ | ៣% | ៥៤% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦៥២,៤ | ៦% | ២៩% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១៥៤,៤ | -១,៥% | ២៦% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤២៧,២ | -៤% | ៥% |
| ✓ តាមផ្លូវអាកាស | ២៧៤,៩ | ២% | ៣៣% |
| ✓ តាមផ្លូវគោក និងទឹក | ១៥២,៣ | -១៤% | -២៤% |

## ៥) ស្ថានភាពពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនា ខែសីហា ឆ្នាំ២០១៧ មានចំនួន៤៣៧១,៨ប៊ីលានរៀល (ស្មើនឹង១០៩២លានដុល្លារ ស.រ.អា.) ថយចុះ៦,៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង០,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | % ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១,៩% | +១៣,៤% | រថយន្តសរុប (ប៊ី.ល.រ) | +១៦,៣% | +២០,៨% |
| ប្រេងម៉ាស៊ូត | +២៤,៩% | +៤២,៨% | រថយន្តសរុប (គ្រឿង) | +១៤,៣% | +០,៨% |
| ឧស្ម័ន | -៣,៧% | +១៨,១% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៣៣% | +៦៧,៤% |
| អគ្គិសនីនាំចូល | -៤៨% | -៨% | ម៉ូតូ (គ្រឿង) | +៣១% | +៤,៣% |
| ដែកសំណង់ | -០,៦% | -៦% | អង្ករ | -២,៩% | -៨២% |
| ស៊ីម៉ង់ត៍ | -១,៤% | +១៨,៨% | ផ្លែឈើនិងបន្លែ | -៦៥,៨% | -១៤,៨% |
| គ្រឿងអេឡិចត្រូនិក | -១០,១% | +៨២,៤% | ជីនិងថ្នាំកសិកម្ម | -២៩,៩% | -១១,៦% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +១០% | +៨,៨% |

➡**ការនាំចេញ** ខែសីហា ឆ្នាំ២០១៧ មានចំនួន**៤៥១៧,៨**ប៊ីលានរៀល ស្មើនឹង១១២៩,៥លានដុល្លារស.រ.អ (១០៣,៣៤% នៃការនាំចូល)កើនឡើង៤,២% ធៀបនឹងខែមុន និងកើនឡើង១៧,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%ធៀបនឹងខែមុន* | *%ធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +២៣,៤% | +៦៧០% | ផលិតផលនេសាទ | +១១៤៨,៦% | +៦១០,៨% |
| វាយនភណ្ឌនិងស្បែកជើង | -២,៥% | +៨,២% | កៅស៊ូ | +១៤,៨% | +៣៨% |
| អង្ករ | +៦៣,៤% | +៧៨,២% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហា ឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃប្រេងសាំង | +៣,១% | +៩,៦% | |
| ២ | ថ្លៃប្រេងម៉ាស៊ូត | +១,១% | +៨,១% | — |
| ៣ | ឧស្សាហកម្មធុនតូច និងសិប្បកម្ម(បើកថ្មី) | -២១% | -៣៩% | |

## ៧) សេចក្តីសន្និដ្ឋាន

សុវត្ថិភាពម្ហូបអាហារជាបញ្ហារសើបបំផុតនៅកម្ពុជា សម្រាប់អ្នកបរិភោគក្នុងស្រុក វិស័យទេសចរណ៍ និងពាណិជ្ជកម្ម ពោលគឺបើផលិតផលម្ហូបអាហារគ្មានសុវត្ថិភាព វានឹងបង្កវិបត្តិសុខភាពសាធារណៈ របាំងនៃការនាំចេញ ឯវិស័យទេសចរណ៍នឹងត្រូវចុះខ្សោយ។ ទស្សនៈវិស័យមួយចំនួនស្តីពីសុវត្ថិភាពចំណីអាហារដែលបានពិភាក្សាមានជាអាទិ៍÷

១)ការនាំចូលផលិតផលម្ហូបអាហារដ៏សន្ធឹកសន្ធាប់នាពេលបច្ចុប្បន្ន ធ្វើឲ្យមានការរងគ្រោះដល់អ្នកបរិភោគនៅកម្ពុជា ក្នុងនោះ អ្នកប្រើប្រាស់ក្នុងស្រុក និងភ្ញៀវទេសចរ

២)ប្រទេសជិតខាងដែលនាំចេញម្ហូបអាហារមកកម្ពុជា ក៏ជួបវិបត្តិសុវត្ថិភាពម្ហូបអាហារដែរ អ្នកប្រើប្រាស់បាត់បង់ទំនុកចិត្ត ព្រោះតែការប្រើប្រាស់សារធាតុគីមីក្នុងកម្រិតដ៏ច្រើនលើសលប់ក្នុងប្រទេសរបស់ខ្លួន។ ឧទាហរណ៍ វៀតណាមនាំចូលបន្លែ ផ្លែឈើ និងសាច់ក្នុងទំហំកាន់តែធំទៅៗពីប្រទេសចិន ថៃ និងដ៏ទៃទៀត រដ្ឋាភិបាលនៃប្រទេសនេះ ក៏រឹតបណ្តឹងវិធានការណ៍ស្តង់ដារម្ហូបអាហារ ដូច្នេះផលិតករមានតែទីផ្សារនាំចេញប៉ុណ្ណោះ ដូចជាកម្ពុជា ដើម្បីរំដោះផលិតផលរបស់ខ្លួន។

៣)ផលិតកម្មនៅកម្ពុជា ក៏មិនឥតខ្ចោះទាក់ទងនឹងការប្រើសារធាតុគីមីនេះ។ បញ្ហាស្ថិតត្រង់ថា អ្នកផលិតទាំងក្នុងស្រុកទាំងក្រៅស្រុក ដើម្បីប្រាក់ចំណេញ មិនគិតគូរដល់ក្រមសីលធម៌ ខិតខំផលិតនិងធ្វើពាណិជ្ជកម្មម្ហូបអាហារដែលគ្មានសុវត្ថិភាព និងផលប៉ះពាល់សុខភាពអ្នកប្រើប្រាស់។ ក្រៅពីនោះ កង្វះបញ្ញត្តិ ការអនុវត្តបញ្ញត្តិ និងយុទ្ធសាស្ត្រ ជុំវិញវិស័យម្ហូបអាហារក៏ជាកត្តាចម្បងនៃវិបត្តិនេះដែរ។

៤)ជំងឺសំខាន់ៗដែលកើតមកពីម្ហូបអាហារគ្មានសុវត្ថិភាព គឺ ជំងឺឆ្លងដូចជា អាសន្នរោគ របេង ប៉ារ៉ាស៊ីត បាក់តេរី និងវីរុសផ្សេងៗ ហើយមួយផ្នែកទៀត ជំងឺក្នុងរាងកាយដូចជា មហារីកក្រពះ ពោះវៀន ថ្លើម លំពែង ជាដើម ដែលតម្រូវឲ្យមានបន្ទុកចំណាយខ្ពស់ ទាំងបុគ្គល ទាំងសាធារណៈ។

៥)ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចៈ កម្ពុជាគឺជាសមាជិកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីមួយចំនួន ដូច្នេះ កំណើននៃការនាំចូលចំណីអាហារដែលមានតម្លៃថោកនិងពោរពេញដោយសារធាតុគីមីដោយគេចមិនផុត។ នេះបង្ហាញពីបញ្ហាប្រឈមចំពោះផលិតកម្មម្ហូបអាហារក្នុងស្រុក ជាពិសេសចំពោះកសិករខ្នាតតូច។ ការណ៍នេះធ្វើឱ្យកសិករ ដាំដុះ ចិញ្ចឹមសត្វមានស្ថានភាពដ៏ពិបាកក្នុងការប្រកួតប្រជែង។

៦)នៅក្នុងរយៈពេលមធ្យម និងវែង កម្ពុជាត្រូវតែអភិវឌ្ឍឲ្យបាននូវផលិតកម្មខ្នាតធំនិងកសិឧស្សាហកម្ម ទើបធានាបានមុខមាត់ជាប្រទេសកសិកម្ម និងសន្តិសុខស្បៀង ដែលមានប្រជាជនភាគច្រើនជាកសិករក្រីក្រ។

៧)អន្តរាគមន៍របស់រដ្ឋ ដែលជាចំណាត់ការ ដូចជា ការចេញបទបញ្ញត្តិ និងវិញ្ញាបនបត្រ ការអនុវត្តយន្តការគ្រប់គ្រង ត្រួតពិនិត្យ សវនកម្ម ត្រូវធ្វើឡើងឲ្យមានប្រសិទ្ធភាពបំផុត និងចំភារកិច្ចតួនាទី ដើម្បីធានាឲ្យបានអតិបរិមានូវសុខភាពអ្នកបរិភោគ និងសុខមាលភាពអ្នកផលិត។

៨)យន្តការត្រួតពិនិត្យ អនាម័យ និងភូតគាមអនាម័យ ត្រូវតែប្រើប្រាស់ឲ្យអស់សក្តានុពល ដើម្បីជាវិធានការច្រោះយកគុណភាពនៃម្ហូបអាហារនាំចូល របាំងពាណិជ្ជកម្មដែលអាចប្រើបានទោះស្ថិតក្នុងកិច្ចព្រមព្រៀងសេដ្ឋកិច្ចសេរីក្តី នឹងសម្រួលដល់លក្ខខណ្ឌនាំចេញ៕

# III- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១៧<br>ម៉ោង០៨:៣០នាទី | ដឹកនាំអង្គសិក្ខាសាលា ស្តីពីកម្មវិធីនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ៨៨៣៤ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/០៩/១៧<br>ម៉ោង០៨:០០នាទី | ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចលេខ ៤៩២/១៧.សសរ/កក/គត ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ការធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុក ក្រុង ឃុំ សង្កាត់ និងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ៣ | ០៤/០៩/១៧<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំក្តាញ់នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/០៩/១៧<br>ម៉ោង១១:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំព្រៃល្វា នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១១/០៩/១៧<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ជូនដល់និស្សិតជ័យលាភី របស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៦ | ១២/០៩/១៧<br>ម៉ោង០៧:៣០នាទី | ចូលរួមជាអធិបតី ក្នុងពិធីបើកសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមប្រធានបទ "ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន" នៅសណ្ឋាគារសុខា ភ្នំពេញ។ |
| ៧ | ១៣/០៩/១៧<br>ម៉ោង១៥:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ក្រោមប្រធានបទ "ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់ អាស៊ាន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខា ភ្នំពេញ។ |
| ៨ | ១៨/០៩/១៧<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | **២៣/០៩/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចលេខ ៦១៥/១៧.សសរ/កក/តក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងប្រកាសសមាសភាពក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកព្រៃកប្បាស និងស្រុកត្រាំកក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ម៉ិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ១០ | **២៥/០៩/១៧ ម៉ោង០៩:៣០នាទី** | បន្តដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **២៥/០៩/១៧ ម៉ោង១៦:៣០នាទី** | ជួបពិភាក្សាការងារជាមួយ លោក **វ៉ាន ឌីណាន** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **២៧/០៩/១៧ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ជីវ សុខហាក់** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **២៨/០៩/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិតជ័យលាភីនៃសាកលវិទ្យាល័យចេនឡា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១៤ | **២៨/០៩/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែសីហា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៩/០៩/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាល បំពាក់គ្រឿងឥស្សរិយយស និងផ្តល់នូវការលើកទឹកចិត្តដល់ លោកព្រឹទ្ធាចារ្យកោសល្យវោហារ **គង់ ណៃ** ដែលទើបទទួលបានពានរង្វាន់សិល្បៈវប្បធម៌ ក្រុងហ្វុគុអូកា ប្រទេសជប៉ុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៦ | **២៩/០៩/១៧ ម៉ោង១៥:៣០នាទី** | ជួបពិភាក្សាការងារជាមួយលោក **លី រស្មី** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in